គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើន
ផលិតភាព ជុំវិញតំបន់ទន្លេសាប
TSTD (ADB TA 7305-CAM)

# បច្ចេកទេសចិញ្ចឹមកង្កែបក្នុងអាង



## ទីតាំងទំនាក់ទំនងទិញកូនកង្កែប

ភ្នំពេញ

- ស្រុក ស្អាង: ម៉ៅ សុជាតិ (មិញ)　　០១២ ៤៣ ៧០ ៤៧

ខេត្តបន្ទាយមានជ័យ

- ក្រុងសិរិសោភ័ណ:　ព្រុំ ថា　　០១២ ១៨០ ៥១ ៧៨
- ក្រុងសិរិសោភ័ណ:　ព្រុំ សារ៉ាន　　០១២ ៩៥ ៧៤ ៨៨

ខេត្តសៀមរាប

- ក្រុងសៀមរាប:　　ជី រដ្ឋា　　០១២ ៣៥ ៦០ ៩០

ឧបត្ថម្ភថវិកាដោយ:
រដ្ឋាភិបាលប្រទេសហ្វាំងឡង់ និង ធនាគារអភិវឌ្ឍន៍អាស៊ី

ខែ មេសា ឆ្នាំ ២០១៣

## សេចក្តីផ្តើម

ការចិញ្ចឹមកង្កែបក្នុងអាង ជារបៀបចិញ្ចឹមថ្មីមួយ ដែលងាយស្រួលក្នុងការថែទាំ គ្រប់គ្រង។ ការចិញ្ចឹមកង្កែបក្នុងអាង មិនសូវត្រូវការទីកន្លែងធំ និង ទឹកច្រើនទេ ដូច្នេះវាមានសមស្រមសម្រាប់អ្នកចង់ចិញ្ចឹម ដែលមានដីតូច និង គ្រាន់តែមានទឹកអណ្តូងមួយ ឬ ស្រះទឹក តូចល្មមមួយ ប៉ុណ្ណោះ។ ម្យ៉ាងទៀត ការចិញ្ចឹមកង្កែបបែបនេះ ប្រើប្រាស់រយៈពេលខ្លី គឺ ពី ២ខែកន្លះ ទៅ៣ ខែ យ៉ាងយូរ ដែលជាហេតុ ធ្វើឱ្យអ្នកចិញ្ចឹម មានលទ្ធភាពចំណេញច្រើន បើសិនជាគាត់អនុវត្តបាន ត្រឹមត្រូវតាមបច្ចេកទេស និងឧស្សាហ៍ព្យាយាម។

ជាទូទៅ ការចិញ្ចឹមកង្កែប អាចប្រើចំណីគ្រាប់ ក៏បាន ឬ កូនត្រីល្អិតៗ ក៏បាន តាមលទ្ធភាពដែលអាចរកបាន ។ ពូជកង្កែប ដែលយកមកចិញ្ចឹម ទទួលបានលទ្ធផលល្អ គឺជា កូនកង្កែប ដែលបានពីការបង្កាត់ ពីព្រោះវាមានភាពស៊ាំទៅ នឹងមជ្ឈដ្ឋានក្នុងអាងចិញ្ចឹម និង ចំណីផ្សំដែលផ្តល់ស៊ី។

## គុណសម្បត្តិនៃការចិញ្ចឹមកង្កែប

- ✧ ប្រើកន្លែងតូច តែបានទិន្នផលខ្ពស់។
- ✧ អាចផលិត/ចិញ្ចឹមបានច្រើនដង ក្នុងមួយឆ្នាំ។
- ✧ ការចិញ្ចឹមកង្កែបក្នុងអាង មានលក្ខណៈសមស្រម សម្រាប់កសិករដែលមិនសូវមានដីធំ ហើយសមស្របសម្រាប់ស្ត្រីទៀតផង។



## តើត្រូវការបច្ចេកទេសអ្វីខ្លះដើម្បីទទួលបានជោគជ័យ ?

### ១. ការជ្រើសរើសទីតាំងសម្រាប់សាងសង់អាង



- ✧ជិតលំនៅដ្ឋាន
- ✧ មិនលិចទឹក នៅរដូវវស្សា
- ✧ កន្លែងដែលមានពន្លឺថ្ងៃគ្រប់គ្រាន់ និង មានប្រភពទឹកស្អាត នៅជិត។

### ២. ការសាងសង់អាង

*២-១ ប្រភេទអាង:* អាងចិញ្ចឹមកង្កែបអាចធ្វើពីស៊ីម៉ង់ ឬ តង់





*២-២ បាតអាង:*

- ➢ បាតអាងចិញ្ចឹមកង្កែប ត្រូវធ្វើឱ្យរាបស្មើ ហើយរលោង ដើម្បីបន្ថយភាពកកិត ដែលអាចធ្វើឱ្យកង្កែបរលោក រលាត់ស្បែក ដែលជាហេតុងាយឆ្លងនូវជម្ងឺ ។
- ➢ បាតអាងចិញ្ចឹមកង្កែប ត្រូវធ្វើឱ្យមានជម្រេលបន្តិច ដែលអាចឱ្យទឹក ងាយស្រួលហូរចេញអស់ពីអាង នៅពេលយើងលាងសំអាតបាតអាង ម្តងៗ។



